ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាខេត្តឧត្តរមានជ័យ
លេខៈ ០៨២១ សជណ.ខុជ

ឧត្តរមានជ័យ,ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រមូលពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ ២០១៣

**យោង** ៖ លិខិតលេខ ១៣៥៤ អពដ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ របស់អគ្គនាយកដ្ឋានពន្ធដារ ស្តីពីការរំលឹកការបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ ២០១៣ ។

**អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ** សូមជូនដំណឹងដល់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ទាំងអស់មេត្តាជ្រាបថា ការបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ ២០១៣ ត្រូវប្រមូលចាប់ពីថ្ងៃជូនដំណឹងនេះតទៅរហូតដល់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០១៣ នៅសាខាពន្ធដារខេត្តឧត្តរមានជ័យ។ ឯការត្រួតពិនិត្យលើការបង់ពន្ធនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៣ តទៅ ។

ម្ចាស់អចលនទ្រព្យទាំងអស់ ទោះត្រូវជាប់ឬមិនត្រូវជាប់ពន្ធលើអចលនទ្រព្យក្តី ត្រូវបំពេញព័ត៌មានអចលនទ្រព្យ ក្នុងទម្រង់លិខិត ដែលផ្តល់ដោយសាលាសង្កាត់ ឬ មន្ត្រីពន្ធដារ ហើយត្រូវប្រគល់វិញក្នុងរយៈពេលយ៉ាងយូរ ១០ ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលទម្រង់លិខិត ព័ត៌មានអចលនទ្រព្យនោះ ។

អចលនទ្រព្យដែលមិនស្ថិតក្នុងករណីលើកលែង និង មានតម្លៃលើសពី ១០០ លានរៀល ត្រូវចុះបញ្ជីដាក់លិខិតប្រកាស និង បង់ពន្ធនៅសាខាពន្ធដារខេត្ត ដែលអចលនទ្រព្យនោះស្ថិតនៅ ។

ការចុះបញ្ជីត្រូវភ្ជាប់មកជាមួយនូវឯកសារថតចម្លងដូចជា អត្តសញ្ញាណបណ្ណ ឬ សំបុត្របញ្ជាក់កំណើត ឬ លិខិតឆ្លងដែន(ជនបរទេស), សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ ឬ លិខិតបញ្ជាក់ទីលំនៅ, បណ្ណសម្គាល់សិទ្ធិ ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់ ឬ វិញ្ញាបនបត្រសម្គាល់ម្ចាស់អលចនវត្ថុដែលចេញដោយរដ្ឋបាលសុរិយោដី ឬ ឯកសារពាក់ព័ន្ធនឹងការកាន់កាប់អចលនទ្រព្យ ដែលបញ្ជាក់ដោយឃុំសង្កាត់ឡើងទៅ ។

អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ សង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ពិតជាមានការភ្ញាក់រលឹកខ្ពស់ ហើយសូមអញ្ជើញមកបំពេញកាតព្វកិច្ចបង់ពន្ធនេះ អោយបានរួសរាន់ទាន់ពេលវេលាកំណត់ជាពុំខានឡើយ ។

**អភិបាលខេត្ត**

ស_ថាវី

**ចម្លងជូន ៖**
- ក្រសួងមហាផ្ទៃ
- អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត

( ដើម្បីជូនជ្រាប )

- សាខាពន្ធដារខេត្ត
- ក្រុមជំនួយការអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ
- ក្រុមការងារអចលនទ្រព្យនៅសង្កាត់ទាំង៥

(ដើម្បីអនុវត្ត)

- ឯកសារ-កាលប្បវត្តិ